# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ
លេខ......០៥៨......សហវ-ក.ជ.គ

រាជធានីភ្នំពេញថ្ងៃទី ២៨ ខែ មិនា ឆ្នាំ២០១៦

## សេចក្ដីជូនដំណឹង
## ស្ដីពីការពន្យារការអនុវត្តស្ដង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា
## សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង

- យោងព្រះរាជក្រមលេខនស/រកម/០៧០២/០១១ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- យោងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ០៦៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ស្ដីពីការដាក់ឱ្យប្រើស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា
- យោងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ១០១ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យប្រើស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ
- យោងសេចក្ដីជូនដំណឹងរបស់ក្រុមប្រឹក្សាជាតិគណនេយ្យលេខ ០៩៧-០៩សហវ-កជគ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការដាក់ឱ្យប្រើស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងការដាក់ឱ្យប្រើស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម
- តាមការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជា តាមលិខិតលេខ ធ៧.០១២.០៤៤.សជណ. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការសុំពន្យារពេលអនុវត្តស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- តាមការស្នើសុំរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការសុំពន្យារពេលអនុវត្តស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង

ក្រុមប្រឹក្សាជាតិគណនេយ្យ សូមជូនដំណឹងដល់គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង ដែលកំពុងតែប្រកបអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

១- គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ មានភារកិច្ចអនុវត្តតាមស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាពាក់ព័ន្ធចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

២- គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយណា ដែលចូលរួមនៅក្នុងទីផ្សារមូលបត្រមានកាតព្វកិច្ចអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាពាក់ព័ន្ធ ស្របតាមប្រកាសលេខ១០១ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ។

៣- ក្នុងដំណាក់កាលអន្តរកាល គឺចាប់តាំងពីកាលបរិច្ឆេទនៃការជូនដំណឹងនេះ រហូតដល់ដំណាច់ឆ្នាំ២០១៨ គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ត្រូវចាត់ឱ្យមានការបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួន រៀបចំប្រព័ន្ធស្ទូលសម្រាប់គ្រប់ប្រតិបត្តិការហិរញ្ញវត្ថុស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា និងរបៀបនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នខ្លួនឱ្យស្របតាមស្តង់ដាទាំងនោះ។

៤- ដើម្បីធានានូវភាពជោគជ័យលើការងារនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ត្រូវធ្វើផែនការសកម្មភាពក្នុងការអនុវត្តស្តង់ដានិងត្រូវធ្វើរបាយការណ៍រៀងរាល់ឆ្នាំ (ដំណាច់ឆ្នាំ២០១៦, ២០១៧, និងឆ្នាំ២០១៨) អំពីវឌ្ឍនភាពជូន ក.ជ.គ និងនិយ័តករពាក់ព័ន្ធ។

៥- ការមិនគោរពតាមសេចក្តីជូនដំណឹងនេះ ត្រូវចាត់ទុកថាជាការល្មើសនឹងច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ និងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ០៦៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា ដែលយោងខាងលើ។

ដូចនេះ គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ត្រូវអនុវត្តនូវសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ. ក្រុមប្រឹក្សាជាតិគណនេយ្យ
ប្រធាន

[illegible]

*ចម្លងជូន*

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួង ស.ហ.វ
  *"ដើម្បីគោរពជូនជ្រាប"*
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុ
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- គ្រប់ក្រុមហ៊ុនសវនកម្ម
  *"ដើម្បីជ្រាប និងជំរុញការអនុវត្ត"*

*កន្លែងទទួល*

- គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រប់ក្រុមហ៊ុនធានារ៉ាប់រង
  *"ដើម្បីអនុវត្ត"*
- គ្រប់សាលារាជធានី-ខេត្ត
  *"ដើម្បីផ្សព្វផ្សាយនិងសហការអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ